**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :..................០៦០/២១..........**ក.ប**/ស.ណ.ស.ខ.ល

## សេចក្តីណែនាំ
## ស្តីពី
## វិធានការបង្ការជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស ក្នុងព្រឹត្តិការណ៍សហគមន៍-២០កុម្ភៈ

ដើម្បីចូលរួមចំណែកបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស ក្នុងអំឡុងព្រឹត្តិការណ៍សហគមន៍-២០កុម្ភៈ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមណែនាំដល់ម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិត ដូចខាងក្រោម៖

១. ត្រូវពង្រឹងការអនុវត្តសេចក្តីណែនាំលេខ០០៤/២០ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ ស្តីពីការអនុវត្តវិធានការបង្ការជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២. ត្រូវរឹតបន្តឹងការអនុវត្តវិធានការសុខាភិបាល ជាពិសេសវិធានការ "៣ការពារ = ការពាក់ម៉ាស, ការលាងដៃ, និងការរក្សាគម្លាតសុវត្ថិភាពសង្គម" និងវិធានការ "៣កុំ = កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូលហើយប្រើម៉ាស៊ីនត្រជាក់, កុំទៅកន្លែងមានមនុស្សច្រើនកុះករដែលមិនដឹងប្រភពច្បាស់លាស់, និងកុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា"។

៣. មិនត្រូវអនុញ្ញាតឱ្យបុគ្គលដែលមិនមែនជាអ្នកគ្រប់គ្រង ឬកម្មករនិយោជិត ឬមន្ត្រីមានសមត្ថកិច្ច ចេញចូលបរិវេណរោងចក្រ សហគ្រាសជាដាច់ខាត។ ទន្ទឹមនឹងនោះ ត្រូវក្តាប់នូវប្រវត្តិនៃការធ្វើចត្តាឡីស័ក និងស្ថានភាពសុខភាពរបស់បុគ្គលិកដែលទើបវិលត្រឡប់មកពីបរទេសឱ្យបានច្បាស់លាស់មុននឹងអនុញ្ញាតឱ្យចូលធ្វើការវិញ។

៤. ត្រូវផ្តល់ព័ត៌មានទៅក្រសួងសុខាភិបាលជាបន្ទាន់ ក្នុងករណីមានរោគសញ្ញាសង្ស័យណាមួយកើតឡើង ចំពោះកម្មករនិយោជិតរបស់ខ្លួន។

៥. ត្រូវអប់រំ ណែនាំ និងលើកទឹកចិត្តឱ្យគ្រប់បុគ្គលិក កម្មករនិយោជិតទាំងអស់កុំគេចវេះពីការធ្វើចត្តាឡីស័ក ដែលការគេចនេះនឹងនាំឱ្យមានហានិភ័យដល់ខ្លួនឯងផង សុខភាពសាធារណៈផង និងត្រូវរងការពិន័យអន្តរកាលផង។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថាម្ចាស់ ឬនាយករោងចក្រ សហគ្រាស និងកម្មករនិយោជិតនឹងអនុវត្តសេចក្តីណែនាំនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

*ថ្ងៃសៅរ៍ ៩កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស២៥៦៤.*

*រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១*

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ក្រសួងសុខាភិបាល
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត

  *"ដើម្បីជូនជ្រាប និងសហការ"*
- គ្រប់អង្គភាព និងមន្ទីរនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

  *"ដើម្បីអនុវត្ត"*
- ឯកសារ កាលប្បវត្តិ